មាត្រា ៣ ._ ស្រុកអន្លង់វែងរួមមានឃុំចំនួន ០៥ គឺ ឃុំអន្លង់វែង ឃុំថ្លាត ឃុំត្រពាំងប្រីយ៍ ឃុំលំទង និង ឃុំត្រពាំងតាវ ។

មាត្រា ៤ ._ ស្រុកអន្លង់វែង ត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោម :

- ខាងជើងទល់ នឹងព្រំប្រទល់ព្រះរាជាណាចក្រថៃឡង់ដ៍
- ខាងកើតទល់ នឹងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ
- ខាងត្បូងទល់ នឹងស្រុកបន្ទាយស្រី និង ស្រុកវ៉ារិន ខេត្តសៀមរាប
- ខាងលិចទល់ នឹងស្រុកសំរោង ខេត្តសៀមរាប

មាត្រា ៥ ._ ទីតាំងសាលាស្រុកអន្លង់វែង ស្ថិតក្នុងឃុំអន្លង់វែង ។

មាត្រា ៦ ._ បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ២៣ អនក្រ.បក
## ស្តីពីការ បង្កើតស្រុកត្រពាំងប្រាសាទ
## ចំណុះខេត្តឧត្តរមានជ័យ

★★★

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៥/០៧ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតខេត្តឧត្តរមានជ័យ
- បានឃើព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ ._ ត្រូវបានបង្កើតស្រុកត្រពាំងប្រាសាទ ដោយកាត់យកភូមិសាស្ត្រមួយចំណែកពីស្រុកអន្លង់វែង ។

មាត្រា ២ ._ ស្រុកត្រពាំងប្រាសាទ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង រដ្ឋបាលរបស់ខេត្តឧត្តរមានជ័យ ។

មាត្រា ៣ ._ ស្រុកត្រពាំងប្រាសាទ ត្រូវបង្កើត ឃុំចំនួន ០៦ គឺ ឃុំ ត្រពាំងប្រាសាទ ឃុំបាក់អន្លូង ឃុំអូរស្វាយ ឃុំព្រះប្រឡាយ ឃុំផ្អាវ នឹង ឃុំ ទំនប់ដាច់ ។

មាត្រា ៤ ._ ស្រុកត្រពាំងប្រាសាទ ត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោម :

- ខាងជើងទល់ នឹងព្រំប្រទល់ព្រះរាជាណាចក្រថៃឡង់ដ៍
- ខាងកើតទល់ នឹងខេត្តព្រះវិហារ
- ខាងត្បូងទល់ នឹងស្រុកស្វាយលើ ខេត្តសៀមរាប
- ខាងលិចទល់ នឹងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

មាត្រា ៥ ._ ទីតាំងសាលាស្រុកត្រពាំងប្រាសាទ ស្ថិតក្នុងឃុំត្រពាំងប្រាសាទ ។

មាត្រា ៦ ._ បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ,ថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ២៤ អនក្រ.បក

## ស្តីពីការ បង្កើតគិលានដ្ឋានជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ